**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ១៩៥៨ **អយក.**ប្រក

# ប្រកាស
# ស្តីពី
# តម្លៃសមមូលនៃសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខនស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ១២ ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី១៥ មិថុនា ឆ្នាំ១៩៩២ ស្តីពីការបើកសាលារៀនចំណេះទូទៅឯកជន
- បានឃើញអនុក្រឹត្យលេខ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញប្រកាសលេខ១១៣០ អយក.ប្រក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការប្តូរឈ្មោះ និងប្តូរគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន «**សាលា ភាពជាអ្នកដឹកនាំ ឡៃហ្គី**» ទៅជា «**សាលា អេឃូគីគី ឡៃហ្គី លីឌីហ្សីប អាកាឌីមី**»
- យោងតាមពាក្យស្នើសុំរបស់លោក **ដូមិនិក ហ្វាប** ជានាយក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤

## សម្រេច

**ប្រការ១ .-**

សញ្ញាបត្របញ្ចប់ការសិក្សាថ្នាក់ទី ១២ ដែលចេញដោយ «**សាលា អេឃូគីគី ឡៃហ្គី លីឌីហ្សីប អាកាឌីមី**» ត្រូវមានតម្លៃសមមូលនឹងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិដែលចេញដោយក្រសួងអប់រំ យុវជន និងកីឡា។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh/ administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

**ប្រការ២ .-**

«**សាលា អេយូតឺតី ឡៃហ្គ័ ឈីឌីហ្សីប អាកាឌីមី**» ត្រូវរៀបចំបញ្ជីឈ្មោះសិស្សដែលបានប្រឡងជាប់ជាស្ថាពរនៅក្នុងកម្មវិធីប្រឡងបញ្ចប់ ដោយភ្ជាប់មកជាមួយនូវពិន្ទុលទ្ធផលសិក្សារបស់សិស្ស ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យនិងផ្ដល់ការឯកភាពមុននឹងចេញវិញ្ញាបនបត្របណ្ដោះអាសន្ន និង/ឬ បោះពុម្ពសញ្ញាបត្រជូនដល់សិស្សដែលបានប្រឡងជាប់ជាស្ថាពរ។

**ប្រការ៣ .-**

ក្រសួងអប់រំ យុវជន និងកីឡា មានសិទ្ធិដកហូត ឬ បដិសេធសញ្ញាបត្រថ្នាក់ទី ១២ ដែលចេញដោយ «**សាលា អេយូតឺតី ឡៃហ្គ័ ឈីឌីហ្សីប អាកាឌីមី**» ក្នុងករណីត្រួតពិនិត្យរកឃើញមានភាពមិនត្រឹមត្រូវក្នុងដំណើរការសិក្សា ឬ មានភាពមិនត្រឹមត្រូវក្នុងការសម្រេចផ្ដល់សញ្ញាបត្រដល់អ្នកសិក្សា។

**ប្រការ៤ .-**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបង្កើតគណៈកម្មការដែលមានសមាសភាពមកពីនាយកដ្ឋានអធិការកិច្ចគុណភាពអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ និងនាយកដ្ឋានជំនាញពាក់ព័ន្ធដើម្បីត្រួតពិនិត្យតាមដានជាប្រចាំលើកម្មវិធីសិក្សា និងដំណើរការសិក្សារបស់ «**សាលា អេយូតឺតី ឡៃហ្គ័ ឈីឌីហ្សីប អាកាឌីមី**» ស្របតាមស្តង់ដារសម្រាប់វាយតម្លៃលើកម្មវិធីសិក្សា និងដំណើរការរបស់គ្រឹះស្ថានសិក្សាឯកជនដែលបណ្ដុះបណ្ដាលកម្មវិធីសិក្សាអន្តរជាតិ។ ស្តង់ដារនេះត្រូវរៀបចំទាបបំផុតឱ្យស្មើនឹងកម្មវិធីសិក្សា របស់ក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានកិច្ចការប្រឡង ប្រធាននាយកដ្ឋានអធិការកិច្ចគុណភាពអប់រំ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ សាកលវិទ្យាធិការ និងនាយកគ្រប់គ្រឹះស្ថានឧត្តមសិក្សាទាំងសាធារណៈនិងឯកជន មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងគ្រឹះស្ថានសិក្សាឯកជន «**សាលា អេយូតឺតី ឡៃហ្គ័ ឈីឌីហ្សីប អាកាឌីមី**» ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១១រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៤

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី

  «*ដើម្បីជូនជ្រាបជាព័ត៌មាន*»

- ដូចប្រការ ៦ «*ដើម្បីអនុវត្ត*»
- កាលប្បវត្តិ.ឯកសារ